Khmer / ខ្មែរ

# អំពីរដ្ឋសភារបស់អ្នក

## កម្រិតនៃរដ្ឋាភិបាល

នៅក្នុងប្រទេសអូស្ត្រាលី មានរដ្ឋាភិបាលបីកម្រិត - មូលដ្ឋាន រដ្ឋ និងសហព័ន្ធ។

**សហព័ន្ធ៖** រដ្ឋាភិបាលកម្រិតសហព័ន្ធគឺទទួលខុសត្រូវចំពោះបញ្ហានានាដែលមានចែងក្នុងរដ្ឋធម្មនុញ្ញអូស្ត្រាលី ដូចជាផ្នែកពន្ធដារ ទំនាក់ទំនងអន្តរជាតិ (កិច្ចការខាងក្រៅ) ការការពារជាតិ ការធ្វើចំណាកស្រុក និងជាច្រើនទៀត។ ច្បាប់ដែលធ្វើឡើងនៅកម្រិតសហព័ន្ធ ត្រូវអនុវត្តនៅទូទាំងប្រទេសអូស្ត្រាលី។

**រដ្ឋ៖** រដ្ឋនានាគឺទទួលខុសត្រូវចំពោះបញ្ហាដែលមិនមានចែងនៅក្នុងរដ្ឋធម្មនុញ្ញអូស្ត្រាលី - គឺជាកិច្ចការផ្សេងៗដែលបានទុកឱ្យរដ្ឋនៅពេលបង្កើតសហព័ន្ធ ។ រដ្ឋដោះស្រាយបញ្ហាធំៗផងដែរដូចជាផ្នែកអប់រំ សុខភាព សេវាកម្មសង្គ្រោះបន្ទាន់ បរិស្ថាន និងអ្វីៗជាច្រើនទៀត។

**មូលដ្ឋាន៖** មានសាលាសង្កាត់មូលដ្ឋាន (ក្រុមប្រឹក្សាមូលដ្ឋាន) រាប់រយនៅទូទាំងប្រទេសអូស្ត្រាលី។ សាលាសង្កាត់ត្រួតពិនិត្យបញ្ហានានានៅជិតផ្ទះដូចជាសេវាកម្មសហគមន៍ សួនកុមារ ការប្រមូលសំរាម និងការអនុញ្ញាតការសាងសង់ជាដើម។

សភារដ្ឋអូស្ត្រាលីខាងត្បូងគឺស្ថិតនៅកម្រិតរដ្ឋ។




## ការបែងចែកសិទ្ធិអំណាច

នៅប្រទេសអូស្ត្រាលីមាន សិទ្ធិអំណាចដើម្បី 1) បង្កើតច្បាប់  2) អនុវត្តច្បាប់ និង 3) ធ្វើការសម្រេចចិត្តលើច្បាប់ ត្រូវបានបែងចែករវាងសាខាផ្សេងៗគ្នារបស់រដ្ឋាភិបាល ដូច្នេះការគ្រប់គ្រងមិនស្ថិតនៅជាមួយស្ថាប័នតែមួយទេ។

**សភា/នីតិប្បញ្ញត្តិ៖** សភាគឺជាអ្នកបង្កើតច្បាប់ចម្បង។ តំណាងរាស្ត្រជាប់ឆ្នោតដែលធ្វើការក្នុងសភា គឺជាអ្នកបង្កើតច្បាប់សម្រាប់ប្រជាពលរដ្ឋ។

**អង្គនីតិប្រតិបត្តិ៖** អង្គនីតិប្រតិបត្តិគឺជារដ្ឋមន្ត្រី (ជួនកាលហៅថាខុទ្ទកាល័យ) និងជាអ្នកបំរើសេវាសាធារណៈដែលធ្វើការក្រោមរដ្ឋមន្ត្រីនៅក្នុងក្រសួងរដ្ឋាភិបាលផ្សេងៗគ្នា។ អង្គនីតិប្រតិបត្តិជាអ្នកអនុវត្តច្បាប់ ឬជាអ្នកដាក់ឱ្យអនុវត្តច្បាប់។ ជាឧទាហរណ៍ គ្រូបង្រៀននៅសាលារដ្ឋត្រូវបានដាក់ឱ្យអនុវត្តច្បាប់ដែលបានបង្កើតឡើងស្ដីអំពីសេវាអប់រំសាធារណៈ។ ឧទាហរណ៍មួយទៀតនៃការងារអង្គនីតិគឺប៉ូលីស ត្រូវអនុវត្តច្បាប់ព្រហ្មទណ្ឌដែលធ្វើឡើងដោយសភាជាកំហិត។

**អាជ្ញាធរតុលាការ៖** អាជ្ញាធរតុលាការតុលាការគឺជាប្រព័ន្ធតុលាការ។ តុលាការមានទំនួលខុសត្រូវចម្បងក្នុងការសម្រេចចិត្តអំពីច្បាប់ ជាឧទាហរណ៍ ការសម្រេចចិត្តថាតើច្បាប់នេះត្រូវបានអនុវត្តត្រឹមត្រូវដែរឬទេ ឬក៏វាត្រូវបានបង្កើតឡើងតែនៅក្នុងវិសាលភាពនៃអំណាចរបស់ខ្លួន។

សភារដ្ឋអូស្ត្រាលីខាងត្បូង គឺជាសាខាសភា/នីតិប្បញ្ញត្តិរបស់រដ្ឋាភិបាល



## សភារដ្ឋអូស្ត្រាលីខាងត្បូង

ច្បាប់រដ្ឋធម្មនុញ្ញ ត្រូវបានប្រកាសនៅក្នុងរដ្ឋអូស្ត្រាលីខាងត្បូង ក្នុងឆ្នាំ1856 ដើម្បីផ្តល់ជូនមន្ទីរសភាពីរ (bicameral)។ មន្ទីរសភាទាំងពីរនេះ ត្រូវបានគេស្គាល់ថាសភាតំណាងរាស្ត្រ និងក្រុមប្រឹក្សានីតិប្បញ្ញត្តិ។ បន្ទាប់ពីការបោះឆ្នោតសម្ងាត់លើកដំបូងមួយរបស់ពិភពលោក សភារដ្ឋដំបូង បានជួបប្រជុំគ្នានៅថ្ងៃពុធ ទី 22 ខែមេសា ឆ្នាំ1857។

**សភាតំណាងរាស្ត្រ៖** សភាតំណាងរាស្ត្រត្រូវបានបង្កើតឡើងដោយសមាជិកសភាចំនួន47រូប។ សមាជិកសភាចំនួន47រូបត្រូវបានជ្រើសរើសឱ្យធ្វើជាតំណាងប្រជាពល រដ្ឋអូស្ត្រាលីខាងត្បូងនៅក្នុងសភាសម្រាប់រយៈពេល4ឆ្នាំ។ សមាជិកសភាម្នាក់តំណាងឱ្យអ្នកបោះឆ្នោតប្រមាណជា 25,000នាក់។ គណបក្ស នយោបាយដែលអាចបង្កើតសមាជិកសភាភាគច្រើននៅក្នុងសភាតំណាងរាស្ត្រ ក្លាយជារដ្ឋាភិបាលរដ្ឋអូស្ត្រាលីខាងត្បូង ហើយពួកគេអាចទទួល បានសមត្ថភាពក្នុងការជ្រើសរើសរដ្ឋមន្ត្រីដែលគ្រប់គ្រងអង្គនីតិប្រតិបត្តិ។ ប្រធានសភារក្សាសណ្តាប់ធ្នាប់ ហើយនិមិត្តសញ្ញានៃសភាតំណាងរាស្ត្រ គឺ ដំបងការិយាល័យ (Mace)។

**ក្រុមប្រឹក្សានីតិប្បញ្ញត្តិ៖** ក្រុមប្រឹក្សានីតិប្បញ្ញត្តិត្រូវបានបង្កើតឡើងដោយសមាជិកចំនួន22រូប (MLCs)។ MLCs ត្រូវបានជ្រើសរើសដោយប្រជាពលរដ្ឋអូស្ត្រាលីខាងត្បូងសម្រាប់រយៈពេល8ឆ្នាំ ហើយ MLCs គឺតំណាងឱ្យរដ្ឋទាំងមូល។ នេះមានន័យថា MLCs ទាំង22រូបជាអ្នកបំរើការសម្រាប់អ្នក។ សន្លឹកឆ្នោតត្រូវបានរាប់ខុសៗគ្នាសម្រាប់ក្រុមប្រឹក្សានីតិប្បញ្ញត្តិ ហើយជារឿយៗមានគណបក្សតូចៗ ឬគណបក្សឯករាជ្យជាច្រើនទៀតនៅក្នុងមន្ទីរសភានេះ ។ប្រធានសភារក្សាសណ្តាប់ធ្នាប់ ហើយនិមិត្តសញ្ញានៃក្រុមប្រឹក្សានីតិប្បញ្ញត្តិគឺដំបងខ្មៅ (Black Ro)។

## មុខងាររបស់សភា

សភាមានមុខងារសំខាន់ៗចំនួន4៖

**តំណាង៖** សភាគឺជាកន្លែងដែលប្រជាជពលរដ្ឋអូស្ត្រាលីខាងត្បូង ត្រូវបានធ្វើជាតំណាងតាមរយៈសមាជិកសភារបស់ពួកគេ។ សមាជិកសភា អាចនិយាយលើបញ្ហាបណ្តឹងតវ៉ា បញ្ហាផលប្រយោជន៍ និងសំណើច្បាប់នានា ដើម្បីធានាថាបញ្ហានានារបស់ប្រជាពលរដ្ឋអូស្ត្រាលីខាងត្បូងត្រូវបានស្តាប់ឮដោយរដ្ឋាភិបាល និងដោយសមាជិកដទៃទៀត ។

**ការត្រួតពិនិត្យ៖** រដ្ឋមន្ត្រីដែលទទួលខុសត្រូវចំពោះក្រសួងរដ្ឋាភិបាលផ្សេងៗគ្នា ក៏ធ្វើការនៅក្នុងសភាផងដែរ។ នេះមានន័យថា តំណាងរបស់អ្នក និងគណបក្សនយោបាយផ្សេងៗគ្នាអាចត្រួតពិនិត្យ និងសាកសួរការងាររបស់ពួកគេ។ សមាជិកសភាអាចសួរសំណួរទៅកាន់រដ្ឋមន្ត្រី ទាំងតាមរយៈវេទិកាសំណួរ (សំណួរដោយគ្មានការជូនដំណឹង) ឬតាមរយៈប្រព័ន្ធសំនួរ "ដោយជូនដំណឹងជាមុន" ។

**ហិរញ្ញវត្ថុ៖** សភាគឺជាកន្លែងដែលការចំណាយរបស់រដ្ឋាភិបាលត្រូវបានអនុម័ត។ ថវិកាត្រូវតែបានអនុម័តជារៀងរាល់ឆ្នាំ។ ជាធម្មតា ថវិកាត្រូវបានណែនាំនៅក្នុងខែមិថុនា សម្រាប់ឆ្នាំហិរញ្ញវត្ថុនាពេលខាងមុខ។។

**នីតិប្បញ្ញត្តិ៖** សភាគឺជាកន្លែងដែលបង្កើត និងផ្លាស់ប្តូរច្បាប់រដ្ឋអូស្ត្រាលីខាងត្បូង។

## អគារ

អគារបុរាណមានសសរថ្មម៉ាប ផ្នែកខាងលើមានក្បាច់ចេនាកូរិនថូស និងការចម្លាក់ថ្មនៃរូបអភិបាលប្រធាន និងប្រធានសភាក្នុងអំឡុងសតវត្សទី19។ សម្ភារសំណង់សំខាន់ៗដែលបានយកមកប្រើប្រាស់គឺថ្មម៉ាបពីតំបន់ Kapunda និងថ្មក្រានីតពីតំបន់ Victor Harbor។ ពណ៌របស់មន្ទីរសភា ធ្វើតាមបែបប្រពៃណីរបស់ចក្រភពអង់គ្លេស ពណ៌ក្រហមសម្រាប់ក្រុមប្រឹក្សានីតិប្បញ្ញត្តិ និងពណ៌បៃតងសម្រាប់សភាតំណាងរាស្ត្រ។ សភាតំណាងរាស្ត្រត្រូវបានបើកសម្ពោធនៅថ្ងៃទី5 ខែមិថុនា ឆ្នាំ1889។ នៅឆ្នាំ 1936 លោក Sir Langdon Bonython បានផ្តល់អំណោយជាទឹកប្រាក់ចំនួន £100,000 ដើម្បីឱ្យការងារអាចត្រូវបានចាប់ផ្តើមសម្រាប់ក្រុមប្រឹក្សានីតិប្បញ្ញត្តិ ដែលបានបើកសម្ពោធនៅថ្ងៃទី5 ខែមិថុនា ឆ្នាំ1939។ រដ្ឋមន្ត្រីទីមួយពីររូប គឺលោក Tom Price (1905-1909) និងលោក Frank Walsh (1965-1967) ទាំងពីររូបជាជាងសាងសង់នៅកន្លែងនោះ។

## ការចូលរួម

**ការទស្សនា៖** មន្ទីរសភាស្ថិតនៅកាច់ជ្រុងផ្លូវ King William Street និង North Terrace។ ការប្រជុំមន្ទីរសភាទាំងពីរគឺបើកស្វាគមន៍សម្រាប់សមាជិកសាធារណៈ និងភ្ញៀវទាំងអស់។ នៅពេលដែលសភាមិនបើកការប្រជុំ ការចូលទស្សនាជាក្រុមដែលមានអ្នកណែនាំ មានផ្តល់ជូននៅម៉ោង 10.00ព្រឹក និងម៉ោង2.00រសៀល រៀងរាល់ថ្ងៃធ្វើការ។ រាល់ការចូលទស្សនាគឺមិនគិតថ្លៃទេ។ ដើម្បីទស្សនាតាមសាលា និងជាក្រុម អ្នកគួរតែកក់ជាមុនតាមរយៈសមាជិកសភាក្នុងតំបន់របស់អ្នក។ ប្រសិនបើអ្នកមិនអាចទស្សនាសភាដោយផ្ទាល់បានទេ អ្នកអាចទស្សនាតាមរយៈការផ្សាយបន្តផ្ទាល់តាមអនឡាញ។

**របាយការណ៍ជាផ្លូវការដែលកត់តាមពាក្យសំដីនិយាយក្នុងសភា (Hansard)៖** របាយការណ៍ជាផ្លូវការដែលកត់តាមពាក្យសំដីនិយាយក្នុងសភា គឺជារបាយការណ៍ផ្លូវការនៃការជជែកដេញដោលរបស់សភា។ អ្នកអាចអានពីរាល់ដំណើរការទាំងអស់របស់សភានៅក្នុងរបាយការណ៍ជាផ្លូវការដែលកត់តាមពាក្យសំដីនិយាយក្នុងសភា។ របាយការណ៍ជាផ្លូវការដែលកត់តាមពាក្យសំដីនិយាយក្នុងសភា គឺមាននៅលើគេហទំព័ររបស់សភា។

**គណៈកម្មការ៖** សមាជិកក្រុមតូចៗត្រូវបានបង្កើតឡើងជាគណៈកម្មការ ដើម្បីអនុវត្តការងារលម្អិតជំនួសឱ្យមន្ទីរសភា។ គណៈកម្មការសភាមានអំណាចទូលំទូលាយដើម្បីប្រមូលយកភស្តុតាង ហើយពិចារណា និងរាយការណ៍អំពីបញ្ហានានាក្នុងលក្ខខណ្ឌយោងរបស់ពួកគេ។ សាធារណជនអាចធ្វើអន្តរកម្មជាមួយគណៈកម្មការនានាដោយធ្វើការដាក់សំណើ និងការបង្ហាញខ្លួននៅក្នុងវេទិកាសាធារណៈបាន។

**ញត្តិ៖** ញត្តិគឺជាការស្នើសុំឱ្យចាត់វិធានការ។ ពលរដ្ឋ ឬក្រុមពលរដ្ឋនៃរដ្ឋអូស្រ្តាលីខាងត្បូងណាក៏ដោយ អាចដាក់ញត្តិទៅសភាដើម្បីចាត់វិធានការ។ ជាឧទាហរណ៍មួយ ញត្តិអាចស្នើឱ្យមន្ទីរសភាណែនាំច្បាប់ ឬលុបចោល ឬកែប្រែច្បាប់ដែលមានស្រាប់ ឬចាត់វិធានការសម្រាប់គោលបំណងជាក់លាក់ ឬជាការពេញចិត្តចំពោះបុគ្គលជាក់លាក់ណាម្នាក់។ ការដាក់ញត្តិសភា គឺជាការបង្កើតសិទ្ធិមូលដ្ឋានដ៏យូរអង្វែងរបស់ប្រជាពលរដ្ឋទាំងអស់។ វាអនុញ្ញាតឱ្យបុគ្គល ឬក្រុមណាមួយអាចដាក់ពាក្យបណ្តឹងនៅចំពោះមុខសភា។ វាជាមធ្យោបាយទំនាក់ទំនងផ្ទាល់មួយរវាងប្រជាពលរដ្ឋ និងសភា ក្នុងចំណោមមធ្យោបាយទំនាក់ទំនងផ្ទាល់មួយចំនួនទៀត។

**ការបាតុកម្ម៖** ការជួបជុំធ្វើបាតុកម្ម ឬបាតុកម្មនៅលើកាំជណ្តើរនៃវិមានរដ្ឋសភាត្រូវបានអនុញ្ញាត ប៉ុន្តែសំខាន់បំផុត អ្នករៀបចំត្រូវទទួលបានការយល់ព្រមពីប្រធានសភា និងប្រធានជាមុនសិន។ នេះជាផលប្រយោជន៍របស់សមាជិកសាធារណជនដែលចូលរួមក្នុងសភា ឬកំពុងប្រើប្រាស់ផ្លូវថ្មើរជើង ឬផ្លូវថ្នល់ និងជាផលប្រយោជន៍នៃអ្នកដែលចូលរួមក្នុងការជួបជុំ ឬការ ជួបជុំធ្វើបាតុកម្ម។

**ទំនាក់ទំនងសមាជិក៖** អ្នកអាចរកមើលព័ត៌មានទំនាក់ទំនងសមាជិកនៅលើគេហទំព័ររបស់យើង ដើម្បីនិយាយទៅកាន់តំណាងរបស់អ្នកអំពីទស្សនៈរបស់អ្នកចំពោះបញ្ហាទាំងឡាយ។

## ការប្រៀបធៀបជាមួយសភាសហព័ន្ធ

| | សភាសហព័ន្ធ | |
|---|---|---|
| | សភាតំណាងរាស្ត្រ | ព្រឹទ្ធសភា |
| ឈ្មោះផ្សេងទៀត | សភាជាន់ទាប | សភាជាន់ខ្ពស់ |
| | 151 | 76 |
| តំណាង | សមាជិកសភាម្នាក់ៗ តំណាងឱ្យអ្នកបោះឆ្នោត ចំនួន110,000នាក់ | សមាជិកព្រឹទ្ធសភាម្នាក់ៗ តំណាងឱ្យរដ្ឋ ឬទឹកដីរបស់ខ្លួន។ មានសមាជិកព្រឹទ្ធសភាចំនួន12នាក់ សម្រាប់រដ្ឋនីមួយៗ និង2នាក់ សម្រាប់ទឹកដីនីមួយៗ។ |
| អាណត្តិ | 3 ឆ្នាំ | 6 ឆ្នាំ |
| ប្រព័ន្ធបោះឆ្នោត | បង្ហាញពីលំដាប់នៃចំណង់ចំណូលចិត្ត | សមាមាត្រ - ការបោះឆ្នោតដែលអាចផ្ទេរ បានតែមួយ |
| អាជ្ញាធរតុលាការ | ច្បាប់ដែលបានអនុម័ត គឺសម្រាប់ប្រទេសអូស្ត្រាលីទាំងមូល | ច្បាប់ដែលបានអនុម័ត គឺសម្រាប់ប្រទេសអូស្ត្រាលីទាំងមូល |

| | សភារដ្ឋអូស្ត្រាលីខាងត្បូង | |
|---|---|---|
| | សភាតំណាងរាស្ត្រ | ក្រុមប្រឹក្សានីតិប្បញ្ញត្តិ |
| ឈ្មោះផ្សេងទៀត | សភាជាន់ទាប | សភាជាន់ខ្ពស់ |
| សមាជិក | 47 | 22 |
| តំណាង | សមាជិកសភាម្នាក់ៗ តំណាងឱ្យអ្នកបោះឆ្នោត ចំនួន25,000នាក់ | សមាជិកក្រុមប្រឹក្សានីតិប្បញ្ញត្តិម្នាក់ៗ តំណាងឱ្យរដ្ឋអូស្ត្រាលីខាងត្បូងទាំងមូល |
| Term អាណត្តិ | 4 ឆ្នាំ | 8 ឆ្នាំ |
| ប្រព័ន្ធបោះឆ្នោត | បង្ហាញពីលំដាប់នៃចំណង់ចំណូលចិត្ត | សមាមាត្រ - បង្ហាញពីលំដាប់នៃចំណង់ចំណូលចិត្តជាជម្រើស |
| អាជ្ញាធរតុលាការ | ច្បាប់ដែលបានអនុម័ត គឺសម្រាប់តែរដ្ឋអូស្ត្រាលីខាងត្បូងប៉ុណ្ណោះ | ច្បាប់ដែលបានអនុម័ត គឺសម្រាប់តែរដ្ឋអូស្ត្រាលីខាងត្បូងប៉ុណ្ណោះ |

## ទាក់ទងមកពួកយើង


**ទូរសព្ទ៖** +61 8 8237 9100 | 1800 182 097 ( ឥតគិតថ្លៃ )

**សរសេរ៖** GPO Box 572, Adelaide SA 5001, Australia

**ទស្សនា៖** Parliament House, North Terrace, Adelaide SA 5000, Australia

**អ៊ីមែល៖** LegCo@parliament.sa.gov.au ( ក្រុមប្រឹក្សានីតិប្បញ្ញត្តិ )

Assembly@parliament.sa.gov.au ( សភាតំណាងរាស្ត្រ )

**គេហទំព័រ៖** www.parliament.sa.gov.au

**ប្រព័ន្ធផ្សព្វផ្សាយសង្គម៖**

Facebook: @parliamentsouthaustralia

Instagram: @parliamentsouthaustralia

YouTube: South Australian Parliament

Twitter: @LegCouncilSA | @AssemblySA